**សុន្ទរកថារបស់លោក ម៉ាត់ស៊ូម៉ូតុ អ៊ីហ្សូមី**

លេខាទី២ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធគម្រោងលើកកម្ពស់មជ្ឈមណ្ឌលសិក្សាសហគមន៍

នៅក្នុងឃុំតាអាន ដំណាក់កាលទី៣

នៃការផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ឆ្នាំ២០១៥

**ថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ២០១៧**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **លោក តាម៉ារី គីយ៉ូតាកា** នាយកអង្គការសន្តិស៊ុំគ្រចិត្ត(SVA)
- សូមគោរព **លោក សយ ទិត្យាវង្ស** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប
- សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស និងអស់លោកលោកស្រីទាំងអស់!

ថ្ងៃនេះ ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយជាខ្លាំង ដែលបានមកចូលរួមក្នុងពិធីសម្ពោធមជ្ឈមណ្ឌលសិក្សាសហគមន៍ថ្មីមួយ នៅក្នុងឃុំតាអាន ជាមួយនឹងវត្តមានរបស់ **លោក សយ ទិត្យាវង្ស** និងភ្ញៀវកត្តិយសទាំងអស់ដែលបានអញ្ជើញចូលរួមនៅក្នុងពិធីសម្ពោធមជ្ឈមណ្ឌលសិក្សាសហគមន៍នាពេលនេះ។ ជាតំណាងអោយស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងសុន្ទរកថានេះដូចតទៅៈ

គម្រោងអនុវត្តការសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍ចំនួន៦ខ្នង ក្នុងនោះមាននៅខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ ដែលក្នុងមួយខេត្តសាងសង់២ខ្នង សម្រាប់រយៈពេល៣ឆ្នាំនេះ ត្រូវបានអនុវត្តដោយអង្គការសន្តិស៊ុំគ្រចិត្ត(SVA) ក្រោមថវិការជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុនដល់អង្គការជប៉ុន ដោយសម្របតាមផែនការយុទ្ធសាស្រ្តអប់រំរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំបានទទួលដំណឹងថា នៅក្នុងឃុំតាអននេះ ជាកន្លែងដែលត្រូវបានសាងសង់មជ្ឈមណ្ឌលសិក្សាសហគមន៍នេះ គឺមានអ្នកភូមិប្រមាណជាងពាក់កណ្តាល មិនទាន់ចេះអាន និងសរសេរដែលជាហេតុធ្វើអោយពួកគាត់ជួបផលលំបាកជាច្រើនក្នុងការរស់នៅប្រចាំថ្ងៃដូចជាៈ ពួកគាត់មិនអាចអានឯកសារ ឬលិខិតនានាដែលចេញដោយអាជ្ញាធរភូមិ-ឃុំ និងជួបបញ្ហាពីគ្រូពេទ្យនានាជាដើម។ ខ្ញុំសង្ឃឹមថា ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅទីនេះ នឹងអាចមកធ្វើការសិក្សាបាន តាមរយៈការមកចូលរួមក្នុងវគ្គបណ្តុះបណ្តាលផ្នែកអក្ខរកម្ម និងសកម្មភាពផ្សេងៗ ដែលមាននៅក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍នេះ។

តាមផែនការ ការរៀបចំមជ្ឈមណ្ឌលសិក្សាសហគមន៍នេះនៅមិនទាន់បញ្ចប់នៅឡើយទេ។ ចាប់ពីថ្ងៃនេះត ទៅសហគមន៍នេះ គប្បីបន្តគ្រប់គ្រងមជ្ឈមណ្ឌលដោយខ្លួនឯងអោយដំណើរការទៅប្រកបដោយនិរន្តរភាព ជាអាទិ៍៖ ការងារអក្ខរកម្ម និងសិក្ខាសាលាជាដើម។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គម្រោងនេះ នឹងរួមចំណែកក្នុងការលើកស្ទួយ កម្រិតជីវភាពរស់នៅរបស់ប្រជាជនទូទៅនៅមូលដ្ឋាន និងប្រជាជននៅភូមិក្បែរៗនេះ។ ដើម្បីទទួលបានជោគជ័យ តាមផែនការ ខ្ញុំសង្ឃឹមថា បងប្អូន អ្នកភូមិទាំងអស់ នឹងប្រើប្រាស់មជ្ឈមណ្ឌលសិក្សាសហគមន៍នេះអោយមាន ប្រសិទ្ធភាព និងជួយថែទាំអោយនៅគង់វង្សយូរអង្វែង ដើម្បីទុកជានិមិត្តរូបនៃទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

នៅទីបញ្ចប់នេះ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះសរចំពោះមន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាប សហគមន៍នៅក្នុងមូលដ្ឋានឃុំតាអាននេះទាំងអស់ ចំពោះសមាជិកអង្គការសន្តិស្ម័គ្រចិត្ត(SVA) ដែលបានរួម ចំណែកធ្វើឱ្យការអនុវត្តគម្រោងនេះប្រព្រឹត្តទៅដោយជោគជ័យ៕

**សូមអរគុណ!**